# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ឧបនាយករដ្ឋមន្ត្រី
លេខ ៣៦៦០ កបទ.សអ.ច្បក២

**<u>សូមជម្រាបមក</u>**

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>កម្មវត្ថុ:</u>** ករណីអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា ចាប់និងឃុំខ្លួនជនបរទេសនៅលើទឹកដីកម្ពុជា

**<u>យោង:</u>** លិខិតលេខ ៨៦៦ រប-០៦ ចុះថ្ងៃទី២២/០៥/២០០៦ របស់តុលាការខេត្តបន្ទាយមានជ័យ

ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមជ្រាបថា កាលពីថ្ងៃទី២២/០៥/២០០៦ តុលាការខេត្តបន្ទាយមានជ័យបានជូនដំណឹងទៅស្ថានទូតថៃ នៅទីក្រុងភ្នំពេញ ដោយផ្ទាល់ អំពីការឃុំខ្លួនជាបណ្ដោះអាសន្នចំពោះជនជាតិថៃ ឈ្មោះណារី ឈុំមនាត ភេទប្រុស អាយុ៣៤ ឆ្នាំ មុខរបរកម្មករ ទីលំនៅបច្ចុប្បន្ន ភូមិបាំងឡា ឃុំតាបប្រាយ៉ា ស្រុកតាបប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈលើក្មេងស្រីខ្មែរ ឈ្មោះ វណ្ណ សុភ័ណ អាយុ១៦ ឆ្នាំ និង បទឆ្លងដែនខុសច្បាប់កាលពីថ្ងៃទី០៦/០៥/២០០៦ ។

ពាក់ព័ន្ធនឹងករណីចាប់ និងឃុំខ្លួនជនបរទេសនៅលើទឹកដីកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យល់ឃើញថា តុលាការគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេសពុំត្រូវធ្វើលិខិតបញ្ជូនព័ត៌មានដោយផ្ទាល់នៅស្ថានទូតបរទេសប្រចាំនៅកម្ពុជាឡើយ គឺត្រូវធ្វើតាមរយៈក្រសួងការបរទេស ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងធ្វើការផ្សព្វផ្សាយទៅតុលាការគ្រប់ ខេត្ត-ក្រុង តាមការគួរ ។

ភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ហោ ណាំហុង**

<u>ចម្លងជូន</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- តុលាការខេត្តបន្ទាយមានជ័យ
- អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា